# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១២៩១.ព្រទ.កយ-២០០២

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ផ្ញើជូន**

**លោកប្រធានតុលាការខេត្ត-ក្រុង**
**លោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង**

**កម្មវត្ថុ:** អំពីការអនុវត្តន៍ការងារបន្ធូរបន្ថយទោស លើកលែងទោស និងសំណើសុំដោះលែងទណ្ឌិតដែលមានផ្ទុកមេរោគអេដស៍ ឬកើតជម្ងឺអេដស៍ ( AIDS ) ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមរំលឹកអស់លោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាថា មកដល់ថ្ងៃនេះចំនួនទណ្ឌិតដែលបានស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសមានចំនួនកើនច្រើនឡើងជាលំដាប់ ។ ក្រសួងបានជួបប្រទះការលំបាកស្មុគស្មាញមួយចំនួនទាក់ទងនឹងពេលវេលា និងភាពខ្វះខាតនៃសំណុំឯកសារ ដែលបញ្ជូនមកពីតុលាការ និងអយ្យការខេត្ត-ក្រុង ។

ដើម្បីរៀបចំបែបបទធ្វើរបាយការណ៍ និងសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការលើកលែងទោស បន្ធូរបន្ថយទោសដល់ទណ្ឌិតដាក់ថ្វាយព្រះមហាក្សត្រទ្រង់ព្រះតម្រិះ និងឡាយព្រះហត្ថលេខាឱ្យបានទាន់ពេលវេលាខ្ញុំសូមលោកប្រធាន និងលោកព្រះរាជអាជ្ញា យកចិត្តទុកដាក់អនុវត្តនូវវិធានសំខាន់ៗដូចតទៅ ៖

១-សំណុំឯកសារស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស ត្រូវចាត់បញ្ជូនឱ្យបានទាន់ពេលវេលាតាមកាលកំណត់ដូចខាងក្រោមនេះ ៖

ក/សម្រាប់ឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ និងបុណ្យពិសាខបូជា ត្រូវលៃលកធ្វើយ៉ាងណាចាត់បញ្ជូនសំណុំឯកសារឱ្យបានមកដល់ទីស្តីការក្រសួងយុត្តិធម៌យ៉ាងតិចមួយខែមុនថ្ងៃទី ១៣ ខែ មេសា នៃឆ្នាំ។

ខ/សម្រាប់ឱកាសបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ និងបុណ្យតាំងតុ អុំទូកអកអំបុកសំពះព្រះខែ ត្រូវលៃលកធ្វើយ៉ាងណាចាត់បញ្ជូនសំណុំឯកសារឱ្យមកដល់ទីស្តីការក្រសួងយ៉ាងហោចណាស់ ពីរខែមុនថ្ងៃទី៣០ ខែតុលា នៃឆ្នាំ ។

២-គ្រប់សម្រង់ ឬសេចក្តីចម្លងសាលក្រមព្រហ្មទណ្ឌ ដែលភ្ជាប់មកជាមួយត្រូវមានចំណារអំពីអានុភាពរបស់វា( ការចូលជាស្ថាពរ នៃសាលក្រម ឬសាលដីកា ) ។

៣-សម្រង់សាលក្រម ឬសេចក្តីចម្លងសាលក្រមទាំងនេះ ត្រូវមានលក្ខណៈអាចមើលឃើញច្បាស់ ឬអាចអានបាន ។

៤-ពិនិត្យលទ្ធភាពដែលអាចបន្ធូរបន្ថយ ឬលើកលែងទោសបានដោយផ្អែកតាមលក្ខខ័ណ្ឌដែលមានកំណត់ក្នុងក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី២០-០៦-៨៨ មុននឹងស្នើមកក្រសួងយុត្តិធម៌ ។

**<u>កត់សម្គាល់</u>**

ក/ទណ្ឌិតម្នាក់អាចទទួលបានការបន្ធូរបន្ថយទោស ឬលើកលែងទោសបានតែម្តងគត់ក្នុងឱកាសនៃពិធីបុណ្យទាំងបីលើក នៃឆ្នាំនីមួយៗ ។

ខ/សំណុំឯកសារស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសទាំងឡាយណាដែលបានមកដល់ទីស្តីការក្រសួងដោយយឺតយ៉ាវ មិនត្រឹមត្រូវតាមកាលវេលាដូចបានកំណត់ក្នុងចំណុច១ និងមិនគ្រប់លក្ខណៈសម្បត្តិដូចបាន

កំណត់ក្នុងចំណុច២-៣ និង ៤ ខាងលើ ក្រសួងនឹងមិនទទួលពិនិត្យចាត់ការតាមសំណើឡើយ ។ ដោយឡែកសំណើសុំដោះលែងទណ្ឌិតដែលមានផ្ទុកមេរោគអេដស៍ ឬកើតជម្ងឺអេដស៍តម្រូវឱ្យមានការធ្វើអធិការកិច្ចវាយតម្លៃ និងមានការឯកភាពពីអគ្គាធិការដ្ឋានកិច្ចការតុលាការរបស់ក្រសួងយុត្តិធម៌ជាមុនសិន ដើម្បីបង្ការនិងជៀសវាងនូវគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗដល់ស្ថានភាពសង្គមដែលប្រព្រឹត្តដោយទណ្ឌិតប្រភេទនេះ ក្រោយពីពួកគេត្រូវបានដោះលែងពីពន្ធនាគារទៅនោះ ។

អាស្រ័យហេតុនេះ សូមលោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញា អនុវត្តតាមការណែនាំនេះឱ្យបានល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ ដើម្បីការពារផលប្រយោជន៍ច្បាប់តទៅ ។

សូមលោកប្រធាន និងលោកព្រះរាជអាជ្ញា ទទួលនូវការស្រឡាញ់រាប់អានដ៏ស្មោះអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២

**រដ្ឋមន្ត្រី**

**នាង ស៊ីផុន**

<u>ចម្លងជូន</u>

-សាលាឧទ្ធរណ៍
-មហាអយ្យការអមសាលាឧទ្ធរណ៍
-តុលាការកំពូល
-មហាអយ្យការអមតុលាការកំពូល
ដើម្បីជូនជ្រាប
-ឯកសារ កាលប្បវត្ត